# ការពារខ្លួនអ្នកពីថ្នាំសម្លាប់សត្វល្អិត

## 1 ចៀសវាង...

- កុំឲ្យថ្នាំសម្លាប់សត្វល្អិតប៉ះត្រូវស្បែក ឬលើខ្លួនរបស់អ្នក។
- សំណល់ថ្នាំសម្លាប់សត្វល្អិតដែលអាចមាននៅក្នុងឬនៅលើ រុក្ខជាតិ ដី ទឹកស្រោចស្រពដំណាំ ត្រាក់ទ័រនិងឧបករណ៍ផ្សេងទៀត និងសម្លៀកបំពាក់ ឬឈុតខោអាវការងារដែលបានប្រើប្រាស់រួច (**PPE**)។
- ថ្នាំសម្លាប់សត្វល្អិតដែលភាយរសាត់ បន្ទាប់ពីអ្នកបានបាញ់ថ្នាំនេះនៅក្បែរៗ។

ពាក់អាវដៃវែង ខោជើងវែង ស្បែកជើង ស្រោមជើង និងមួក ឬកន្សែង ដើម្បីការពារខ្លួនអ្នកពីសំណល់ថ្នាំសម្លាប់សត្វល្អិត។




## 2 នៅឆ្ងាយ...

- ពីតំបន់ដែលបានបាញ់ថ្នាំនេះនៅពេលដែលគេប្រាប់ នៅពេលដែលអ្នកឃើញផ្លាកសញ្ញាបង្ហាញ និងពេលដែលកំពុងបាញ់ថ្នាំសម្លាប់សត្វល្អិត (តំបន់ហាមឃាត់ពេលបាញ់ថ្នាំ)។




## 3 លាងសម្អាត...

- ដៃរបស់អ្នកភ្លាមមុនពេលអ្នកញ៉ាំ ផឹក ជក់បារី ទំពារស្ករកៅស៊ូ ឬថ្នាំជក់ និងមុនពេលប្រើបង្គន់ ឬទូរសព្ទរបស់អ្នក។
- រាងកាយ និងសក់របស់អ្នកឲ្យជ្រះជាមួយទឹក សាប៊ូ និងសាប៊ូកក់សក់ ហើយពាក់សម្លៀកបំពាក់ស្អាតបន្ទាប់ពីធ្វើការរួច។ ។
- សម្លៀកបំពាក់ធ្វើការរបស់អ្នកបន្ទាប់ពីរៀងរាល់ការប្រើប្រាស់ម្តងៗ។ ទុកដោយឡែកពីសម្លៀកបំពាក់ផ្សេងក្រៅពីសម្លៀកបំពាក់ធ្វើការ។




## 4 ចាត់វិធានការ...

- ប្រសិនបើថ្នាំសម្លាប់សត្វល្អិតកំពប់ ឬបាញ់លើខ្លួនអ្នក សូមលាងសម្អាតភ្លាម។ ទឹក សាប៊ូ និងកន្សែងត្រូវតែមាននៅក្បែរនោះ (សម្ភារបន្សាបជាតិបំពុល)។ បើមិនមានក្បែរនោះទេ សូមលាងជម្រះជាមួយទឹកស្អាតចេញពីប្រភពទឹកឈូ ទឹកអូរ ឬបឹង។
- លាងសម្អាតខ្លួន និងសក់របស់អ្នកជាមួយនឹងទឹក សាប៊ូ និងសាប៊ូកក់សក់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយពាក់សម្លៀកបំពាក់ស្អាត។



**រកជំនួយផ្នែកវេជ្ជសាស្ត្រឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប្រសិនបើអ្នកគិតថាថ្នាំសម្លាប់សត្វល្អិតបានធ្វើឱ្យមានរបួស ជំងឺ ឬពុល។**

### ក្នុងគ្រាអាសន្ន៖

**រកជំនួយផ្នែកវេជ្ជសាស្ត្រនៅក្បែរនោះ៖**

ឈ្មោះ៖ ____________________

អាសយដ្ឋាន៖ ____________________

ទូរសព្ទ៖ ____________________

**ប្រសិនបើអ្នកត្រូវការរថយន្តសង្គ្រោះបន្ទាន់ សូមប្រាប់ពួកគេ៖**

ឈ្មោះ៖ ____________________

អាសយដ្ឋាន៖ ____________________

ទូរសព្ទ៖ ____________________

### សំណួរ ឬក្តីកង្វល់៖

**ហៅទូរសព្ទទៅទីភ្នាក់ងារគ្រប់គ្រងថ្នាំសម្លាប់សត្វល្អិតរបស់រដ្ឋ ឬកុលសម្ព័ន្ធ៖**

ឈ្មោះ៖ ____________________

អាសយដ្ឋាន៖ ____________________

ទូរសព្ទ៖ ____________________

ចំពោះព័ត៌មានស្តីពីការព្យាបាលវេជ្ជសាស្ត្រ សូមទូរសព្ទទៅមជ្ឈមណ្ឌលគ្រប់គ្រងជាតិពុល តាមរយៈលេខ៖

**1.800.222.1222**

EPA

មានសំណួរអំពីថ្នាំសម្លាប់សត្វល្អិតទេ? សូមទូរសព្ទទៅកាន់លេខ៖

**1.800.858.7378**

(មជ្ឈមណ្ឌលជាតិព័ត៌មានថ្នាំពុល)